# ការអប់រំរបស់លោកអភិបាល អូលីវីយេ
# អំពីអដ្ឋិធាតុរបស់សន្ត លូវីស និងសន្តី ហ្សីលី ម៉ាតាំង
# ទិវានៃការត្រាស់ហៅនៅភ្នំពេញថ្មី ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៩
## គំរូរបស់ឪពុកម្តាយណែនាំឲ្យកូនស្គាល់សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់

ពេលនិយាយអំពីគ្រួសារ ជាឱកាសមួយដើម្បីនឹកឃើញដល់គ្រួសារយើងសិន គិតអំពីជីវិតយើងប្រចាំថ្ងៃ។ ដោយសារយើងរៀងៗខ្លួន យើងចេញពីគ្រួសារមួយហើយយើងរស់នៅក្នុងគ្រួសារមួយ យើងមានឪពុកម្តាយ យើងមានលោកតាលោកយាយ។ ជួនកាលឪពុកយើងស្លាប់ឬម្តាយស្លាប់ឬតាយាយស្លាប់ហើយ ប៉ុន្តែយើងដឹងថាយើងមានឪពុកម្តាយបានបង្កើតយើងដឹងថាយើងបានរស់នៅពីកុមាររហូតដល់ពេលនេះ នៅក្នុងគ្រួសារមួយរួមជាមួយបងប្អូនដែលបានស្រឡាញ់យើង ឬមិនសូវស្រឡាញ់យើងដែរដោយសារជីវិតរបស់យើង បទពិសោធន៍របស់យើងខុសៗគ្នាអំពីក្រុមគ្រួសារ។ ថ្ងៃនេះ ជាឱកាសមួយដើម្បីនឹករលឹកដល់ជីវិតរបស់គ្រួសារដ៏វិសុទ្ធដែលស្ថិតនៅជាមួយយើង។

នៅក្នុងកោដ្ឋនេះ មានធាតុរបស់សន្តលូវីស និងសន្តីហ្សីលី (ហ្សីលី កើតនៅឆ្នាំ១៨៣១ ស្លាប់នៅឆ្នាំ១៨៧៧ និង លូវីស កើតនៅឆ្នាំ១៨២៣ស្លាប់នៅឆ្នាំ១៨៩៤)។ លូវីស ពេលគាត់នៅក្មេងគាត់ចង់ធ្វើជាបូជាចារ្យ ដូច្នេះគាត់ត្រៀមខ្លួនចូលទេវវិទ្យាល័យដើម្បីទៅជាបូជាចារ្យ ប៉ុន្តែគេបានពិនិត្យមើលថាគាត់ខ្សោយភាសាឡាតាំងដែលភាសាព្រះសហាគមន៍ពីដើម។ ពេលយើងនិយាយភាសាឡាតាំងបាន ទើបរៀនទេវវិទ្យាបាន ប៉ុន្តែគាត់ធ្លាក់ដូច្នេះគេឲ្យគាត់ចេញ។ ហ្សីលីគាត់មានគំនិតមួយចង់ធ្វើជាបងស្រី ដូច្នេះគាត់ចូលនៅក្នុងក្រុមគ្រួសារមួយពេលគាត់នៅជាយុវនារី ប៉ុន្តែក្រោយមកគេឃើញគាត់ធ្វើបងស្រីមិនបាន គេក៏ឲ្យគាត់ចេញ។ លូវីស ពេលគាត់ចេញពីទេវៈ គាត់ទៅធ្វើជាងនាឡិកា និង ហ្សីលី គាត់ធ្វើជាជាងប៉ាក់។

ទាំង២នាក់ គេធ្វើការ គេអត់ដែលស្គាល់គ្នាទេ មានថ្ងៃមួយគេដើរនៅលើស្ពានមួយ គេមើលមុខគ្នាទៅវិញទៅមក នៅពេលនោះដូចជាបេះដូងរបស់គេចាប់ផ្តើមលោតខ្លាំងៗ គេគិតថា នេះជាប្តីខ្ញុំនៅថ្ងៃអនាគត នេះជាប្រពន្ធខ្ញុំនៅថ្ងៃអនាគត ៣ខែក្រោយមកគេបានរៀបការជាមួយគ្នា។ អស្ចារ្យ ដោយសារម្នាក់ចង់ធ្វើជាបូជាចារ្យ ម្នាក់ចង់ធ្វើជាបងស្រី ព្រះជាម្ចាស់ឲ្យគេជួបគ្នានៅលើស្ពាន ក្រោយមកគេរៀបការ។ ពេលគេរៀបការគេគិតថា នេះជាគម្រោងការណ៍របស់ព្រះជាម្ចាស់សម្រាប់យើង ការហើយគេនឹកឃើញព្រះជាម្ចាស់បានបង្កើតបុរសនិងស្ត្រី ឲ្យបុរសនិងស្ត្រីទៅជាប្តីប្រពន្ធ ឲ្យប្តីប្រពន្ធនេះបង្កើតកូន និងគ្រប់គ្រងត្រួតត្រាផែនដីទាំងមូល។ ដូច្នេះ២នាក់

នោះគេគិតថា ពិតមែនយើងចង់មានកូនច្រើនគេគិតថាយើងមានកូនច្រើន យើងមានឱកាសច្រើនដើម្បីឲ្យកូនយើងស្គាល់ព្រះជាម្ចាស់ និងនៅថ្ងៃអនាគតជួបជាមួយព្រះជាម្ចាស់នៅស្ថានបរមសុខ។ ទាំង២នាក់ មានកូន៩នាក់ មានទី១ម៉ារី ជាបងស្រីសម្ងាត់ ទី២ ប៉ូលីន ជាបងស្រីសម្ងាត់ ទី៣ លេអូនី ជាបងស្រីក្នុងក្រុមមួយទៀត ទី៤ ហេឡែន ស្លាប់នៅអាយុ៦ឆ្នាំ ទី៥ យ៉ូសែបលូវីស ស្លាប់នៅអាយុ៥ខែ ទី៦ យ៉ូសែបហ្សំហានបាទីស្ទ ស្លាប់នៅអាយុ៨ខែ ទី៧ សេលីន ជាបងស្រីសម្ងាត់ ទី៨ មេឡែន តេរេសា ស្លាប់នៅអាយុ២ខែ និងទី៩ តេរេសា ជាបងស្រីសម្ងាត់។ នេះជាក្រុមគ្រួសាររបស់គាត់ មានកូន៤នាក់បានស្លាប់ ដោយសារសម័យនោះអត់សូវមានថ្នាំនិងគ្រូពេទ្យ និងកូនស្រី៥នាក់ដែលនៅរស់ ព្រះជាម្ចាស់បានណែនាំឲ្យគេធ្វើជាបងស្រី។ ក្នុងចំណោម៥នាក់ មានបងស្រីម្នាក់ដែលយើងស្គាល់ច្បាស់ គឺសន្តី តេរេសា នៃព្រះកុមារយេស៊ូ។

នេះជាគ្រួសារមួយ ដែលរស់នៅក្នុងជីវិតជាប្តីប្រពន្ធដែលអប់រំកូនៗ ប្តីប្រពន្ធដែលមានទុក្ខលំបាក ហើយទុក្ខលំបាកមួយធំបំផុតគឺមានកូនស្លាប់៤នាក់ ហើយទុក្ខលំបាកមួយទៀតធំមែនទែនសម្រាប់គ្រួសារ គឺហ្សេលី ពេលគាត់អាយុ៤៦ឆ្នាំគាត់មានជំងឺមហារីកសុដន់ ដែលមិនអាចព្យាបាលបាន ៨ខែក្រោយមកគាត់ទទួលមរណភាព។ នៅពេលហ្នឹង តេរេសា មានអាយុតែ៤ឆ្នាំ នេះជាទុក្ខលំបាកដែលគេជួបនៅក្នុងគ្រួសាររបស់គេ។

**"រីឯយើងវិញ យើងបានស្គាល់ព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ក្នុងចំណោមយើង ហើយយើងក៏បានជឿ។ ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ អ្នកណាស្ថិតនៅជាប់នឹងសេចក្តីស្រឡាញ់ អ្នកនោះស្ថិតនៅជាប់នឹងព្រះជាម្ចាស់ ហើយព្រះជាម្ចាស់ក៏ស្ថិតនៅជាប់នឹងអ្នកនោះដែរ"** *១យហ ៤,១៦*។ ក្នុងនេះ មានចំណុច២ដែលសំខាន់ គឺទី១ ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ នៅក្នុងអត្ថបទគម្ពីរទាំងអស់នៅក្នុងសម្ពន្ធមេត្រីចាស់ និងសម្ពន្ធមេត្រីថ្មីយើងមានពាក្យនេះតែម្តងគត់ គឺ **"ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់"** នៅក្នុងយ៉ូហាន។ នៅពេលយើងមើលនៅក្នុងសម្ពន្ធមេត្រីចាស់រហូតដល់សម្ពន្ធមេត្រីថ្មី យើងមើលឃើញយ៉ាងជាក់ស្តែងអំពីរបៀបដែលព្រះជាម្ចាស់ស្រឡាញ់យើង។ គម្ពីរទាំងមូល បានបង្ហាញអំពីលក្ខណៈរបស់ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ នៅក្នុងអត្ថបទនីមួយៗយើងមើលឃើញរបៀបដែលព្រះជាម្ចាស់ស្រឡាញ់មនុស្សលោក។ ព្រះជាម្ចាស់បានបង្កើតបុរសនិងស្ត្រី ដោយសារព្រះជាម្ចាស់ស្រឡាញ់មនុស្សលោក ដូច្នេះនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គបានចេញជាបុរសនិងស្ត្រី។

បើយើងគិតមួយភ្លែត ព្រះជាម្ចាស់មានឫទ្ធានុភាពសព្វប្រការ ព្រះជាម្ចាស់មានអ្វីៗទាំងអស់ នៅពេលព្រះជាម្ចាស់បានបង្កើតបុរសនិងស្ត្រី ណែនាំឲ្យព្រះជាម្ចាស់ចាប់ផ្តើមឈឺក្បាលដោយសារមនុស្សយើងខូច។ ភ្លាមៗអាដាំ និងអេវ៉ា បរិភោគផ្លែឈើដែលគ្មានសិទ្ធិញ៉ាំ ភ្លាមៗកាអ៊ី

ននិងអាប៉ែលសម្លាប់គ្នា ភ្លាមៗមនុស្សយើងចង់សាងសង់កំពូលមួយឈ្មោះកាប៊ែល ដើម្បីបង្ហាញថាយើងធំជាងព្រះជាម្ចាស់ ភ្លាមៗមនុស្សយើងចាប់ផ្ដើមធ្វើសង្គ្រាមសម្លាប់គ្នាទៅវិញទៅមក។ ព្រះជាម្ចាស់ស្រឡាញ់យើងយ៉ាងជាក់ស្ដែង ព្រះជាម្ចាស់សង្គ្រោះយើងរហូត អត់ដែលចោលយើងទេ នៅពេលប្រជារាស្ត្ររបស់ព្រះអង្គជាប់ជាទាសកររបស់អេហ្ស៊ីប មានលោកម៉ូសេណែនាំឲ្យគេចេញដើម្បីមានសេចក្ដីសុខនិងមានសេរីភាព។ ឲ្យគេចេញដើម្បីមានសេចក្ដីសុខ មនុស្សយើងចាប់ផ្ដើមស្ដីឲ្យព្រះជាម្ចាស់ អត់មានអ្វីបរិភោគ ៤០ឆ្នាំនៅលើវាលរហោស្ថាន ហើយព្រះជាម្ចាស់ឈឺក្បាលមែនទែន។ ក៏ប៉ុន្តែដោយសារព្រះជាម្ចាស់ស្រឡាញ់មនុស្សលោក ព្រះអង្គបានចាត់ព្រះបុត្រាឲ្យយាងមកដើម្បីរំដោះយើង ជាថ្ងៃព្រះយេស៊ូប្រសូត។ យើងបានឃើញរបៀបព្រះយេស៊ូ បង្ហាញសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ដូច្នេះពេលយើងនិយាយថាព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់ ពេលយើងមើលរបៀបដែលព្រះជាម្ចាស់និងយើង របៀបដែលព្រះជាម្ចាស់ចងសម្ពន្ធមេត្រីជាមួយយើង របៀបដែលព្រះជាម្ចាស់ចាត់ព្រះបុត្រាឲ្យយាងមក របៀបដែលព្រះយេស៊ូបានណែនាំឲ្យអ្នកក្រីក្រ អ្នកតូចតាច អ្នកជម្ងឺមានសេចក្ដីសង្ឃឹម យើងឃើញរបៀបដែលព្រះជាម្ចាស់ស្រឡាញ់យើង នៅពេលមនុស្សយើងបានសម្លាប់ព្រះយេស៊ូនៅលើឈើឆ្កាង នៅពេលហ្នឹងព្រះជាម្ចាស់បានណែនាំឲ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ និងណែនាំឲ្យយើងទាំងអស់ពោរពេញដោយសេចក្ដីសង្ឃឹមនៅក្នុងជីវិតអស់កល្បជានិច្ច។

ដូច្នេះ ពេលយើងមើលគម្ពីរទាំងអស់យើងមើលឃើញផ្ទាល់ភ្នែក អំពីរបៀបដែលព្រះជាម្ចាស់ស្រឡាញ់យើង។ ពេលយើងមើលគ្រួសារហ្នឹង យើងមើលឃើញផ្ទាល់ភ្នែកអំពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះយើង។ ហ្សីលី និង លូវីស ស្រឡាញ់គ្នាមែនទែន ពីថ្ងៃដំបូងរហូតដល់ថ្ងៃចុងក្រោយ និងគេចេះតែបង្ហាញសញ្ញានៃសេចក្ដីស្រឡាញ់ដែលគេមាន។ នៅសម័យហ្នឹងអត់មានទូរស័ព្ទ អត់មានអ្វីដើម្បីទាក់ទងគ្នា គេទាក់ទងគ្នាដោយសរសេរសំបុត្រដើម្បីលើកទឹកចិត្តគ្នាទៅវិញទៅមក។ ជាពិសេស នៅពេលដែល លូវីស ចេញធ្វើដំណើរដើម្បីរកស៊ី គេបង្ហាញអំពីសេចក្ដីស្រឡាញ់ដែលគេមាន និង ហ្សីលី គាត់សរសេរថា "**ថ្ងៃនេះ ខ្ញុំសប្បាយចិត្តណាស់ ដោយសារថ្ងៃនេះខ្ញុំដឹងថាបងនឹងត្រឡប់មកវិញពីធ្វើដំណើរឆ្ងាយ ថ្ងៃនេះខ្ញុំធ្វើការមិនកើតទេ ដោយសារខ្ញុំត្រេកអរពេកកំពុងទន្ទឹងរង់ចាំបងដែលត្រឡប់មកវិញ ពីអូនដែលស្រឡាញ់បងលើសពីជីវិតផ្ទាល់ខ្លួនទៀត**"។ គាត់សរសេរថែមទៀតថា "**នៅពេលបងអត់នៅ ខ្ញុំប្រៀបដូចជាត្រីដែលគេចាប់យកចេញពីទឹក**" គាត់មានអារម្មណ៍ដូចនេះ ពេលប៉ាវាអត់នៅដូចជាខ្វះភាពកក់ក្ដៅនៅក្នុងចិត្ត ដូចត្រីដែលអត់មានទឹក។ គាត់សរសេរថែមទៀត "**ខ្ញុំភ្ជាប់ចិត្តគំនិត ពីព្រឹកដល់យប់ជាមួយបងទោះបីនៅឆ្ងាយក៏ដោយ ខ្ញុំមិនអាចរស់នៅពេលបងទៅឆ្ងាយពីខ្ញុំ**" គេបង្ហាញអំពី

របៀបដែលគេស្រឡាញ់គ្នា សេចក្តីស្រឡាញ់គ្នានេះណែនាំឲ្យយើងមើលឃើញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់នៅក្នុងជីវិតជាប្តីប្រពន្ធ។

លូវីស នៅពេលគាត់ធ្វើដំណើរ២ថ្ងៃ៣ថ្ងៃគាត់សរសេរសំបុត្រទៅប្រពន្ធគាត់ថា "**ខ្ញុំមានអារម្មណ៍ថា ពេលវេលាយូរមែនទែនខ្ញុំទន្ទឹងរង់ចាំថ្ងៃដែលខ្ញុំនៅជិតអូន ពីប្តីដែលស្រឡាញ់ប្រពន្ធយ៉ាងខ្លាំង ប្តីដែលជាមិត្តសម្លាញ់ដ៏ពិតប្រាកដរបស់អូន និងដែលស្រឡាញ់អូនអស់មួយជីវិត**"។ សេចក្តីស្រឡាញ់ដែលគេមាន ពីមួយថ្ងៃទៅមួយថ្ងៃណែនាំឲ្យគេមើលឃើញរបៀបដែលព្រះជាម្ចាស់ស្រឡាញ់យើង។ តេរេសានៃព្រះកុមារយេស៊ូ នៅពេលគាត់ចាប់ផ្តើមនឹកឃើញដល់សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ គាត់នឹកឃើញឪពុកម្តាយគាត់ គាត់និយាយថា "**របៀបដែលឪពុកខ្ញុំស្រឡាញ់ខ្ញុំ របៀបដែលឪពុកខ្ញុំស្រឡាញ់ម្តាយខ្ញុំធ្វើឲ្យខ្ញុំយល់អំពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់សម្រាប់ខ្ញុំ**" របៀបដែលឪពុកម្តាយថែរក្សាកូនៗដោយយកចិត្តទុកដាក់។ នៅពេល ហ្សឺលី ជិតស្លាប់គាត់អធិដ្ឋានជារៀងរាល់ថ្ងៃ និងនិយាយទៅកូនៗថា "**កុំព្រួយបារម្ភពីម៉ាក់ ម៉ាក់បានផ្ញើកូនទៅប៉ាឲ្យមើល ឲ្យស្រឡាញ់ ឲ្យថែរក្សាហើយ ពេលម៉ាក់ឡើងស្ថានបរមសុខ ម៉ាក់អធិដ្ឋានសម្រាប់កូនថែមទៀត យើងជាប់គ្នាថ្ងៃណាមួយយើងបានជួបគ្នាវិញ**" សេចក្តីស្រឡាញ់នេះ គឺជាសេចក្តីស្រឡាញ់ដ៏ពិសេស។

ពេល ហ្សឺលី នៅក្មេងនៅក្នុងគ្រួសារគាត់ គាត់មិនដែលស្គាល់សេចក្តីស្រឡាញ់សោះ ឪពុកម្តាយអត់ស្រឡាញ់គាត់ទេ។ ហ្សឺលី នៅក្នុងក្រុមគ្រួសារក្រីក្រមែនទែន គាត់មិនដែលស្គាល់ភាពកក់ក្តៅសោះ ក្នុងក្រុមគ្រួសាររបស់គាត់អត់ស្គាល់សេចក្តីស្រឡាញ់ អត់មានភាពកក់ក្តៅ អត់មានការលើកទឹកចិត្តពីម្តាយទេ។ ប៉ុន្តែ នៅពេលគាត់បានបង្កើតគ្រួសារផ្ទាល់ខ្លួន គាត់មិនធ្វើតាមបទពិសោធន៍ដែលគាត់មានពេលគាត់នៅក្មេង គាត់យកចិត្តទុកដាក់ ដោយនឹកឃើញសេចក្តីស្រឡាញ់ដែលគាត់ទទួលពីព្រះជាម្ចាស់ ដើម្បីណែនាំឲ្យកូនៗរបស់គាត់ពោរពេញដោយសេចក្តីស្រឡាញ់ និងភាពកក់ក្តៅ។ នេះសំខាន់ណាស់ ជួនកាលនៅក្នុងគ្រួសារយើង យើងពិបាកដែរ ភាពកក់ក្តៅក៏ស្ទើរ សេចក្តីស្រឡាញ់ក៏ស្ទើរ ជួនកាលឪពុកទៅឆ្ងាយចោលម៉ែ ជួនកាលម្តាយគាត់ឈឺ **តើយើងធ្វើដូចម្តេចពេលយើងកសាងគ្រួសារទាំងដែលយើង មិនដែលស្គាល់ភាពកក់ក្តៅនិងសេចក្តីស្រឡាញ់ពីគ្រួសារ?** ជួនកាលយើងឃើញឪពុកប្រើអំពើហឹង្សាក្នុងគ្រួសារ ផឹកស្រា ជក់បារី មានស្រីក្រៅ... **តើខ្ញុំធ្វើដូចម្តេចដើម្បីឲ្យខ្ញុំនឹកឃើញព្រះបិតាស្រឡាញ់ខ្ញុំ?** ពេលយើងស្តាប់ជីវិតរបស់ លូវីស និង ហ្សឺលី ណែនាំឲ្យយើងគិតថាយើងអាចជោគជ័យបាននៅក្នុងជីវិត។ ទោះបី បទពិសោធន៍របស់យើងស្ទើរនៅក្នុងសេចក្តីស្រឡាញ់ ឲ្យយើងនឹកឃើញរបៀបដែលព្រះជាម្ចាស់ស្រឡាញ់យើង។ ដូច ហ្សឺលី គាត់ដឹងថាព្រះជាម្ចាស់មិនដែលចោលគាត់ គាត់ភ្ជាប់

ជាមួយព្រះជាម្ចាស់មែនទែន និងគាត់ខិតខំណែនាំឲ្យកូនៗរបស់គាត់ស្គាល់សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ ដូច្នេះ ពេលគេនិយាយថាព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ **"រីឯយើងវិញយើងបានស្គាល់ព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ក្នុងចំណោមយើង"** ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ ប៉ុន្តែយើងបានស្គាល់សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ក្នុងចំណោមយើង ដោយសារយើងមានបទពិសោធន៍ជាក់ស្តែង អំពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់សម្រាប់យើង។ មិនមែនជាទស្សនៈមួយ ប៉ុន្តែយើងមើលឃើញរបៀបដែលគ្រួសារនេះបានយកចិត្តទុកដាក់គ្នាទៅវិញទៅមក របៀបដែលប្តីប្រពន្ធស្រឡាញ់គ្នា របៀបដែលគេរស់នៅក្នុងសេចក្តីស្រឡាញ់យើងឃើញ។

**សេចក្តីរបស់ឪពុកម្តាយសម្រាប់កូន** ហ្សីលីន ពេលម្តាយស្លាប់ហើយគាត់បានសរសេរពីឪពុករបស់គាត់ថា "**ឪពុករបស់យើងមានបេះដូង មានសេចក្តីស្រឡាញ់ដ៏អស្ចារ្យសម្រាប់យើងគាត់រស់នៅសម្រាប់យើងទាំងស្រុង គាត់មានសេចក្តីស្រឡាញ់ដូចម្តាយ**"។ សន្តី តេរេសា នៅពេលគាត់នឹកឃើញអំពីសេចក្តីស្រឡាញ់របស់ឪពុកគាត់ គាត់ចាប់ផ្តើមគិតអំពីសេចក្តីស្រឡាញ់របស់ព្រះបិតាសម្រាប់គាត់ និងគាត់ចាប់ផ្តើមបង្កើតផ្លូវដ៏តូចតាចដើម្បីណែនាំឲ្យយើងមានសេចក្តីសុខ **តើយើងស្គាល់ផ្លូវដ៏តូចតាចរបស់សន្តីតេរេសាឬទេ?** អនាគតរបស់យើងចង់ទៅស្ថានបរមសុខដើម្បីមានជីវិតអស់កល្បជានិច្ច។ យើងក្រីក្រក្តី យើងជាអ្នកមានក្តី យើងមានពេលវេលា២ដូចគ្នាគឺថ្ងៃយើងកើត និងថ្ងៃស្លាប់ ជីវិតរបស់យើងមានប៉ុណ្ណឹងកើតរហូតដល់ស្លាប់។ ប៉ុន្តែ សម្រាប់យើងសេចក្តីសង្ឃឹមរបស់យើងគឺស្ថានបរមសុខ ដើម្បីមានជីវិតអស់កល្បជានិច្ច។ សន្តី តេរេសា បាននឹកឃើញ **តើខ្ញុំធ្វើយ៉ាងម៉េចដើម្បីឡើងស្ថានបរមសុខ?** ស្តាប់គម្ពីរដូចជាពិបាក ព្រះយេស៊ូមានព្រះបន្ទូលថា "**សត្វអូដ្ឋចូលនៅក្នុងប្រហោងម្ជុល ស្រួលជាងចូលទៅស្ថានបរមសុខសម្រាប់យើង**"។ ពេលឮដូចនេះ តេរេសា គាត់ចាប់ផ្តើមគិតហើយគាត់មើលឃើញរូបភាពដែលឪពុកម្តាយស្រឡាញ់គ្នា គាត់មើលឃើញរបៀបដែលឪពុកម្តាយស្រឡាញ់ព្រះជាម្ចាស់ សន្តី តេរេសា និយាយថា "**ដើម្បីស្ថានបរមសុខ ប្រសិនបើខ្ញុំឡើងតាមជណ្តើរធម្មតាពិបាកដូចព្រះយេស៊ូនិយាយចង្អៀតណាស់ ដូច្នេះខ្ញុំត្រូវការឡើងតាមជណ្តើរយន្ត**"។ តើយើងរកជណ្តើរយន្តពីណាមក? គាត់មើលឃើញដៃរបស់ព្រះយេស៊ូ ទុកឲ្យព្រះយេស៊ូចាប់ដៃខ្ញុំដើម្បីធ្វើដំណើរនៅក្នុងពិភពលោកនេះដើម្បីដល់ស្ថានបរមសុខ។ គាត់នឹកឃើញដោយសារគាត់មើលឃើញរបៀបដែលឪពុកម្តាយស្រឡាញ់ និងរបៀបដែលឪពុកម្តាយភ្ជាប់ជាមួយព្រះជាម្ចាស់ ដែលជាសេចក្តីស្រឡាញ់។

នៅសម័យ ហ្សីលី និង លូវីស មនុស្សយើងកោតខ្លាចព្រះជាម្ចាស់ណាស់ ប៉ុន្តែគ្រួសារនេះមិនខ្លាចព្រះជាម្ចាស់ទេ ដោយសារគេដឹងថាព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់។ តេរេសា ធ្លាប់បាន

និយាយថា "**ទោះបីខ្ញុំប្រព្រឹត្តអំពើបាបធំជាងគេ ខ្ញុំដឹងថាព្រះជាម្ចាស់ស្រឡាញ់ខ្ញុំ**" នៅពេល តេរេសា នៅក្មេង ពេលគាត់ធ្វើខុសម្តាយស្តីឲ្យ គាត់និយាយទៅម្តាយសុំទោសកូនបានធ្វើខុស ក្រោយមកម្តាយគាត់ដើរមករកកូនហើយឲ្យស្ករគ្រាប់សូកូឡា ធ្វើឲ្យ តេរេសា សប្បាយចិត្តណាស់។ ប៉ុន្តែគាត់យល់ពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ "**ពេលខ្ញុំទទួលស្គាល់កំហុសរបស់ខ្ញុំព្រះជាម្ចាស់លើកលែងទោសឲ្យខ្ញុំ**"។ គាត់មិនខ្លាចព្រះបិតាវិនិច្ឆ័យ កាត់ក្តីគាត់ ដោយដឹងថាយើងត្រូវការយកចិត្តទុកដាក់ដើម្បីណែនាំឲ្យព្រះជាម្ចាស់សប្បាយចិត្ត និងឪពុកម្តាយខិតខំអប់រំកូនឲ្យល្អដើម្បីឆ្លើយតបនឹងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ស្រឡាញ់ខ្ញុំយ៉ាងណា ខ្ញុំយកចិត្តទុកដាក់ដើម្បីឲ្យព្រះជាម្ចាស់សប្បាយចិត្តយ៉ាងនោះ ពេលខ្ញុំធ្វើខុសខ្ញុំទទួលស្គាល់និងព្រះជាម្ចាស់លើកលែងទោសឲ្យខ្ញុំ។ កូនឃើញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ នៅក្នុងរបៀបដែលម្តាយបានស្រឡាញ់កូន។

គោលបំណងយ៉ាងធំនៅក្នុងជីវិតរបស់យើង គឺទៅជាសន្ត សន្តី ហ្សេលី គាត់ធ្លាប់និយាយថា "**ខ្ញុំចង់ធ្វើជាសន្តីមួយរូប ប៉ុន្តែខ្ញុំមិនដឹងថាធ្វើយ៉ាងម៉េចដើម្បីធ្វើជាសន្តីបាន ខ្ញុំធ្វើយ៉ាងម៉េចដើម្បីទៅជាមនុស្សដែលជាប់ជាមួយព្រះជាម្ចាស់ ខ្ញុំអត់ដឹងចាប់ផ្តើមពីណាទៅណា ប៉ុន្តែនៅក្នុងដួងចិត្តរបស់ខ្ញុំ ខ្ញុំថែរក្សាគោលបំណងធ្វើជាសន្តី**"។ នៅថ្ងៃអនាគតយើងនឹងមើលឃើញព្រះយេស៊ូផ្ទាល់ យើងទៅជាដូចព្រះជាម្ចាស់ ប្តីប្រពន្ធនេះមានគំនិតនេះ យើងអត់ដឹងធ្វើយ៉ាងម៉េចធ្វើជាសន្តសន្តី ក៏ប៉ុន្តែយើងមានគោលបំណងភ្ជាប់ជាមួយព្រះជាម្ចាស់អស់មួយជីវិត។ ដើម្បីភ្ជាប់ជាមួយព្រះជាម្ចាស់អស់មួយជីវិត គេបង្រៀនឲ្យកូនគេចូលនៅក្នុងហ្នឹង។ ជីវិតគ្រួសារនេះ ព្រឹកឡើងម៉ោង៥ភ្ញាក់ពីដេក ពេលគេកំពុងពាក់អាវឲ្យកូនគេនិទានអំពីរឿងព្រះយេស៊ូ សម័យហ្នឹងអត់សូវមានគម្ពីរដូចយើងមានសព្វថ្ងៃ ដូច្នេះគេនិទានរឿងពីព្រះយេស៊ូឲ្យកូនៗគេស្តាប់។ រួចហើយប្រមូលកូនៗគេទាំងអស់ដើម្បីអធិដ្ឋានខ្លីៗ ក្រោយមកគេទៅអភិបូជារាល់ថ្ងៃ។ ប្តីប្រពន្ធនោះគេយល់ថា យើងត្រូវការមានចាប់ផ្តើមថ្ងៃថ្មី ដោយទទួលព្រះអំណោយទានរបស់ព្រះជាម្ចាស់សម្រាប់ជីវិតយើង។ សម័យហ្នឹង គេទទួលព្រះកាយ១ឆ្នាំ២ដង៣ដង គេទទួលតែថ្ងៃបុណ្យធំៗ ប៉ុន្តែគ្រួសារហ្នឹងទទួល១អាទិត្យ៤ដង ជួនកាលរាល់ថ្ងៃដោយយកចិត្តទុកដាក់ទទួលអគ្គសញ្ញាលើកលែងទោស ដោយយកចិត្តទុកដាក់អធិដ្ឋាន ដោយយកចិត្តទុកដាក់លះបង់ចោលខ្លះៗនៅក្នុងជីវិត។ លូវីស គាត់ចូលចិត្តជក់បារី ប៉ុន្តែដើម្បីភ្ជាប់ជាមួយព្រះជាម្ចាស់ថែមទៀត ដើម្បីលះបង់ចោលគាត់សម្រេចចិត្តឈប់ជក់បារី គាត់លះបង់ចោល និងយកចិត្តទុកដាក់ដើម្បីរស់នៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។ រៀងរាល់ថ្ងៃចន្ទ គ្រួសារគាត់បើកទ្វារផ្ទះដើម្បីស្វាគមន៍អ្នកក្រីក្រ ដើម្បីលើកទឹកចិត្ត មានថ្នាំខ្លះៗ មានម្ហូបខ្លះៗ… នៅក្នុងព្រះសហគមន៍គ្រួសារគេជាគ្រួសារសកម្ម។ ពេលគ្រួសារគេដូរទៅ

រស់នៅទីក្រុងលីស្សឺ ទីនោះអត់មានកម្មវិធីអធិដ្ឋានមួយយប់ទេ ប៉ុន្តែដោយគាត់មានបទពិសោធន៍អធិដ្ឋានមួយយប់ ដូច្នេះគាត់បានបង្កើតឲ្យមានកម្មវិធីអធិដ្ឋានពេញមួយយប់នៅក្នុងព្រះសហគមន៍នៅទីនោះ ដើម្បីឲ្យគ្រីស្តបរិស័ទភ្ជាប់នឹងព្រះជាម្ចាស់។ ពេលចេញពីអភិបូជាហើយគេធ្វើការធម្មតា កូនទៅសាលា ប៉ុន្តែដោយនឹកឃើញព្រះជាម្ចាស់រហូត។ ពេលយប់ញ៉ាំបាយហើយ គេប្រមូលគ្រួសារម្តងទៀតដើម្បីអធិដ្ឋានមុនចូលដេក ដើម្បីអរព្រះគុណព្រះជាម្ចាស់ ដើម្បីសុំទោសសម្រាប់ថ្ងៃហ្នឹង និងដើម្បីសូមឲ្យព្រះជាម្ចាស់ថែរក្សាគេ។

ហេតុនេះហើយ ជីវិតរបស់គាត់បីដូចជារស់នៅក្នុងផ្លូវនៃសុភមង្គល **"ព្រះជាម្ចាស់បានត្រាស់ហៅយើងដើម្បីមានសុភមង្គល"**។ គេយកចិត្តទុកដាក់ដើម្បីរស់នៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហ្សឺលីន និយាយថា **"នៅផ្ទះយើង បីដូចជាយើងរស់នៅពីព្រឹកដល់ល្ងាចក្នុងបរិយាកាសនៃការអធិដ្ឋាន"** មិនមែនថាគេអធិដ្ឋានគ្រប់ពេលវេលា ប៉ុន្តែគេរស់នៅក្នុងបរិយាកាសរបស់ព្រះជាម្ចាស់ បីដូចជាភ្ជាប់ជាមួយវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងពេញមួយថ្ងៃ។ អាចថែមថា **"ព្រះជាម្ចាស់ដូចជាសមាជិកនៅក្នុងក្រុមគ្រួសារនេះ"** នៅក្នុងគ្រួសារនេះបីដូចជាព្រះជាម្ចាស់គង់នៅ។ ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ ប៉ុន្តែព្រះជាម្ចាស់មានវត្តមាន និងព្រះជាម្ចាស់ជាសមាជិកក្នុងគ្រួសារនេះ ណែនាំឲ្យគេរស់នៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់គ្រប់ពេលវេលា។ គេគោរពព្រះជាម្ចាស់ ដោយសារដឹងថាព្រះជាម្ចាស់មានវត្តមានគ្រប់ពេលវេលា។ លូវីស ធ្លាប់និយាយថា **"ព្រះជាម្ចាស់បានចាប់កំណើតជាមនុស្ស ទៅជាទារកមួយរូប តើយើងធ្វើយ៉ាងម៉េចដើម្បីខ្លាចព្រះជាម្ចាស់?"** ពេលយើងឃើញកូនង៉ែតដែលទើបតែកើត អ្នកណាក៏សប្បាយចិត្តស្វាគមន៍គេ ដូច្នេះធ្វើយ៉ាងម៉េចដើម្បីខ្លាចព្រះជាម្ចាស់ដែលចាប់កំណើតជាមនុស្ស? នេះជារបៀបដែលគ្រួសារនេះ រស់នៅពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីណែនាំឲ្យកូនរបស់គាត់រស់នៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ និងណែនាំឲ្យគេយល់ថាព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់យ៉ាងជាក់ស្តែង។

គេយកចិត្តទុកដាក់ ដើម្បីរស់នៅក្នុងឧបការគុណរបស់ព្រះជាម្ចាស់ ឧបការគុណយើងទទួលស្គាល់ព្រះជាម្ចាស់បានបង្កើតយើង ព្រះជាម្ចាស់ថែរក្សាយើង និងព្រះជាម្ចាស់ជាម្ចាស់នៃជីវិតយើងដូចជាម្ចាស់នៃពិភពលោក។ គ្រួសារនេះ រស់នៅក្នុងឧបការគុណរបស់ព្រះជាម្ចាស់ជានិច្ច ដោយដឹងថាអ្វីៗទាំងអស់មកពីព្រះជាម្ចាស់។ នៅពេល ហ្សឺលី គាត់ដឹងថានៅប៉ុន្មានខែទៀតគាត់ស្លាប់ គាត់មិនដែលអស់សង្ឃឹមទេ ជួនកាលគាត់សុំ **"ឱព្រះជាម្ចាស់! សូមជួយខ្ញុំឲ្យខ្ញុំជាសាស្បើយដើម្បីកូនខ្ញុំ ប៉ុន្តែប្រសិនបើព្រះជាម្ចាស់មានព្រះហឫទ័យផ្សេងខ្ញុំទទួល"** គាត់ទទួលដោយសារគាត់ដឹងថា ទោះបីគាត់ស្លាប់ក៏ដោយក៏ព្រះជាម្ចាស់នឹងថែរក្សាគ្រួសារគាត់តទៅទៀត

ទោះបីឥតមានម្ដាយនៅក្នុងក្រុមគ្រួសារនេះ គាត់ដឹងថាព្រះជាម្ចាស់នឹងថែរក្សាគ្រួសារគាត់ ដោយសារគាត់ទុកចិត្តលើឧបការគុណរបស់ព្រះជាម្ចាស់ ព្រះជាម្ចាស់ថែរក្សា ព្រះជាម្ចាស់មិនដែលចោលយើងទេ។ ជួនកាល យើងមានសំណួរថា **មូលហេតុអ្វីមានអំពើបាប អំពើអាក្រក់ មានសង្គ្រាមប្រសិនបើព្រះជាម្ចាស់ស្រឡាញ់យើង? មូលហេតុអ្វីបានជាម្ដាយដែលមានអាយុទើបតែ៥៦ឆ្នាំត្រូវស្លាប់ ទុកឲ្យកូនក្លាយជាកុមារកំព្រាប្រសិនបើព្រះជាម្ចាស់ស្រឡាញ់យើង? មូលហេតុអ្វីកូនគាត់៤នាក់ស្លាប់ប្រសិនបើព្រះជាម្ចាស់ស្រឡាញ់យើង?** ហ្សីលី ធ្លាប់និយាយថា "**កុំនិយាយដើមព្រះជាម្ចាស់ ព្រះជាម្ចាស់ជាម្ចាស់ ព្រះជាម្ចាស់មិនចង់ឲ្យយើងមានទុក្ខលំបាក ហើយយើងដឹងថាព្រះជាម្ចាស់សង្គ្រោះយើងជានិច្ច និងមិនដែលខ្វះព្រះអំណោនទានដែលមកពីព្រះជាម្ចាស់**"។ មុនស្លាប់ គាត់ប្រមូលប្ដីនិងកូនៗគាត់ និងគាត់ថា "**កុំភ័យ កុំព្រួយបារម្ភ គាត់ដឹងថាព្រះជាម្ចាស់នឹងថែរក្សាគ្រួសារយើងតទៅទៀត**"។ ហ្សីលី និយាយទៅព្រះជាម្ចាស់ពេលអំពីកូនគាត់ដែលស្លាប់ថា "**ប៉ុន្មានដងខ្ញុំឈឺចាប់ ពេលខ្ញុំបិទភ្នែករបស់កូនខ្ញុំប៉ុន្តែខ្ញុំដឹងថា នៅថ្ងៃណាមួយខ្ញុំជួបកូនខ្ញុំនៅស្ថានបរមសុខ**" គ្រួសារនេះ រស់នៅក្នុងបរិយាកាសព្រះជាម្ចាស់ដូចព្រះនាងម៉ារី។ ឪពុកគាត់មិនចង់ឲ្យកូនគាត់ទាំង៥នាក់ដែលនៅរស់ធ្វើជាបងស្រីទេ ប៉ុន្តែគាត់និយាយថា "**ប្រសិនបើ ជាព្រះហឫទ័យរបស់ព្រះជាម្ចាស់ទៅចុះ**" ដោយសារឪពុកម្ដាយនេះបានទុកសេរីភាពឲ្យកូន សំខាន់ឲ្យកូនមានអំណរសប្បាយនិងសេចក្ដីសុខ។

ឪពុកបានណែនាំកូនគេឲ្យស្គាល់ពិភពច្រើន រហូតគាត់នាំ តេរេសា ឲ្យជួបជាមួយសម្ដេចប៉ាប នៅទីក្រុងរ៉ូម។ នៅពេលនោះ តេរេសា មានអាយុ១៥ឆ្នាំ គាត់ចង់ធ្វើជាដូនជីសម្ងាត់ ប៉ុន្តែលោកអភិបាលគាត់មិនអនុញ្ញាតដោយសារគាត់ក្មេងពេកអត់ទាន់គ្រប់អាយុ។ ពេលទៅដល់រ៉ូម គាត់ក្លាហានណាស់ដោយនិយាយទៅសម្ដេចប៉ាបថា "**សូមអនុញ្ញាតឲ្យខ្ញុំចូលអារាមសម្ងាត់ផង**" សម្ដេចប៉ាបឆ្លើយថា "**សូមធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ចុះ**"។ លូវីស នៅពេលគាត់ជិតស្លាប់គាត់ចាប់ផ្ដើមវង្វេងស្មារតី ពេលគាត់ដឹងខ្លួនគាត់ទាមទារឲ្យទៅអធិដ្ឋានចូលអភិបូជាគ្រប់ពេលវេលា មុនគាត់ស្លាប់ គាត់និយាយទៅកូនស្រី៥នាក់ថា "**កុំបារម្ភ ដោយសារប៉ាជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់**"។ ខ្ញុំជូនពរឲ្យយើងទាំងអស់ដែលជាគ្រីស្តបរិស័ទ ជាយុវជនយុវនារី ជាបងប្រុសបងស្រី ជាបូជាចារ្យ ជាលោកអភិបាល ឲ្យយើងយកចិត្តទុកដាក់ដើម្បីធ្វើជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់៕